សម្លេងខ្មែរនៅបរទេស

# កាលណាទឹកថ្លាដូចកញ្ចក់ គេមើលឃើញត្រីហែល !

ដោយ សុទ្ធ-ប៉ូលិន ★ ថ្ងៃទី២២ កក្កដា ២០០៥

កាលណាបើគេចាត់ទុកថា «ព្រឹត្តិការណ៍ថ្ងៃ១៨មិនា១៩៧០» ជាទង្វើរបស់ឧត្តមសេនិយលន់-នល់ នោះក៏ដូចជាការសម្លឹងមើលទៅក្នុងទឹកល្អក់ គឺមិនអាចមើលឆ្លុះបានទេ ។ ក៏ប៉ុន្តែប្រសិនបើគេចាត់ទុកថា ជាទង្វើរបស់ស្តេចសីហនុវិញ នោះទឹកនឹងក្លាយទៅជាថ្លាឆ្វង់ដូចកញ្ចក់ ដែលអនុញ្ញាតឲ្យមើលឃើញត្រីហែលក្នុងទឹកបាន ។ តាមពិតឧត្តមសេនិយលន់-នល់ គ្រាន់តែជាកូនត្រីដែលស្តេចសីហនុយកទៅប្រកៃ ក្នុងគោលបំណងឲ្យផាំ-យ៉ាំងដុងត្របាក់លេបតែប៉ុណ្ណោះ ព្រមជាមួយនឹងប្រជាជនខ្មែរ ហើយព្រមជាមួយគ្នានិងទឹកដីកម្ពុជា ។

សម្តេចសីហនុបានចោទប្រកាន់ (មួលបង្កាច់) ឧត្តមសេនិយលន់-នល់ថាបានធ្វើ«រដ្ឋប្រហារនៃថ្ងៃ១៨មិនា១៩៧០»ទម្លាក់ព្រះអង្គ ក្នុងគោលបំណងបំរើផលប្រយោជន៍របស់«ចក្រពត្តិអាមេរិក» ។ ដូច្នេះយើងអាចសម្លឹងមើលពេញភ្នែក ព្រមទាំងធ្វើការវិភាគដល់ទីជំរៅ អំពីទង្វើនិងពាក្យសំដីរបស់ឧត្តមសេនិយលន់-នល់កាលពីសម័យនោះ និងអំពីអាកប្បកិរិយារបស់ក្រុមជនអាមេរិកាំង ដែលកាន់អំណាចនៅសេតវិមាន នៅក្នុងកាលសម័យជាមួយគ្នាដែរ ។ ម្ល៉ោះហើយក្នុងប្រការសើរើកកាយពិនិត្យរឿងចាស់ឡើងវិញទាំងអស់នេះ យើងអាចសម្លឹងមើលឆ្លុះដូចកញ្ចក់ ថាតើជនណាជាអ្នកស្មោះត្រង់នឹងជាតិពិតប្រាកដ (ជាតិខ្មែរ មិនមែនជាតិយួននោះទេ) ហើយតើជនណាជាអ្នកឃុបឃិតក្បត់ជាមួយនឹងជនណា ដើម្បីបោកបញ្ឆោតរុញច្រានប្រទេសកម្ពុជាឲ្យធ្លាក់ទៅក្នុងសេចក្តីវិនាសអន្តរាយ ។

⌘

⌘ ⌘

អត្ថបទផ្សាយក្នុងសារពត៌មាន **Réalités cambodgiennes** នៅភ្នំពេញថ្ងៃ ៨មេសា១៩៧០ ÷

«គោលបំណងរបស់ឧត្តមសេនិយលន់-នល់

«កាលពីល្ងាចថ្ងៃច័ន្ទ (ថ្ងៃទី៣០មិនា១៩៧០) ដោយពិនិត្យមើលសភាពការណ៍ នៅមុខអ្នកសារពត៌មានច្រើនគ្នា, លោកនាយករដ្ឋមន្ត្រីបានធ្វើសេចក្តីបញ្ជាក់ថា ប្រការអំពាវនាវស្វែងរកជំនួយបរទេស នឹងត្រូវលើកយកមកថ្លឹងថ្លែង តែនៅក្នុងលក្ខណ:ណា ដែលសភាពការណ៍ធ្លាក់ដុនដាបប៉ុណ្ណោះ ហើយប្រសិនណាយើងអស់មានមធ្យោបាយផ្លូវទូត ដើម្បីជំរុញពួកជនបរទេសឲ្យដើរចេញពីដីខ្មែរ ។ លោកឧត្តមសេនិយលន់-នល់ដោយមានសំណើចញញឹមធម្មតា បានធ្វើសេចក្តីបញ្ជាក់យ៉ាងដាច់ខាតថា លោកមិនត្រូវការមានអន្តរាគមន៍នៃពួកកងទ័ពបរទេសសោះឡើយ ។ នៅក្នុងប្រការចាំបាច់, ប្រទេសកម្ពុជានឹងអាចស្នើសុំដល់ប្រជាជាតិជាមិត្ត (លោករាប់ឈ្មោះជាឧទាហរណ៍ មានសហរដ្ឋអាមេរិក, បារាំង និងឥណ្ឌូណេស៊ី) នូវគ្រឿងអាវុធជាបន្ថែមប៉ុណ្ណោះ ។ គោលបំណងនេះមានលក្ខណ: សមស្របនឹងសុភនិច្ឆ័យ បើគេគិតថានរោត្តម-សីហនុបានសន្យា ដោយមានបង្អែកពីប៉េកាំងហើយនិងហាណូយ ថានឹងបញ្ជូនគ្រឿងអាវុធកុម្មុយនិស្តទៅដល់ពួក«បះបោរ» ពោលទៅដល់ពួកខ្មែរឃៀកមិញ និងពួកក្រុមខ្មែរដទៃទៀតដែលចាញ់បញ្ឆោតការឃោសនារបស់ឃៀកមិញនិងរបស់ស្តេច ។

លោកនាយករដ្ឋមន្ត្រីបានរំឭកអំពីការប្រឹងប្រែងរបស់រដ្ឋាភិបាលលោក ដើម្បីចៀសវាងមិនឲ្យមានការប៉ះទង្គិចគ្នាខ្លាំងក្លា រវាងកងទ័ពខ្មែរនិងទ័ពវៀតណាម ដោយលោកមានការសោកស្តាយចំពោះការធ្វើដំណើរចាកចេញនៃប្រតិភូរបស់ហាណូយនិងរបស់«រណសិរ្សរំដោះ» (វៀតកុង) ព្រមទាំងលោកបានបន្ថែមទៀតថា ពុំមាន«ការផ្តាច់មិត្តភាព»នោះទេ គ្រាន់តែការលើកទំនាក់ទំនងតាមផ្លូវទូតប៉ុណ្ណោះ ។ លោកឧត្តមសេនិយបានគូសសំគាល់ថា ពួក«យៀកណាមសង្គមនិយម» បានទទួលស្គាល់អព្យាក្រឹត្យភាពនិងបូរណភាពទឹកដីនៃប្រទេសកម្ពុជា ហើយម្យ៉ាងវិញទៀត «ពួកយើងក៏ធ្លាប់មានវត្តមានជាមួយគ្នា នៅសន្និសិទនៃទីក្រុងបាន់ឌុង ដែលកាលនោះគេបានលើកតម្កើងគោលការណ៍ (បញ្ចសិលា) មិនជ្រៀតជ្រែកចូលបញ្ហាផ្ទៃក្នុងនៃប្រទេសដទៃ» ។ លោកឧត្តមសេនិយលន់-នល់បានធ្វើសេចក្តីបញ្ជាក់ អំពីឆន្ទ:នៃប្រជាពលរដ្ឋខ្មែរទូទៅ ដែលចង់រស់នៅជានិច្ចក្នុង«អព្យាក្រឹត្យភាពនិងសេរីភាព»... ហើយឧបមាបើមានការសុំជំនួយផ្នែកសម្ភារ:ទៅដល់មហាអំណាចដែលជាមិត្ត ក្នុងប្រការការពារអព្យាក្រឹត្យនិងសេរីភាពរបស់ខ្លួន ពួកជនជាតិខ្មែរនឹងមិនអនុញ្ញាតឲ្យនរណាម្នាក់ មកច្បាំងតស៊ូជំនួសខ្លួននោះទេ ។ «យើងជាខ្មែរ», លោកពោល «ទាមទារកិត្តិយសប្រយុទ្ធដោយខ្លួនឯង» ។

ពាក្យសំដីពោរពេញដោយមោទនភាពនេះ បានត្រូវគេពុះពាសពេញទាំងនៅក្នុងប្រទេសផង ទាំងខាងក្រៅប្រទេសផង ។ ពាក្យសំដីនេះបានបញ្ចប់ពាក្យចចាម់អារាមដែលផ្សព្វផ្សាយថា នៅក្នុងលក្ខណ:នៃវិបត្តិធ្ងន់ធ្ងរឬអាសន្នអន់ក្រ រដ្ឋាភិបាលនឹងមានលទ្ធភាពសុំជំនួយកងទ័ពបរទេស ។ ដូច្នេះទោះនៅក្នុងវិស័យផ្លូវទូតក្តី ក្នុងវិស័យយោធាក្តី, លោកឧត្តមសេនិយនៅតែមានភក្តីភាពស្មោះត្រង់ជានិច្ចជាមួយនឹងឧត្តមគតិសង្គមរាស្ត្រនិយម ដែលនរោត្តម-សីហនុក្នុងឋាន:ជាស្ថាបនិកបានបោះបង់ចោល» ។

★★★ ខ្លួនខ្ញុំក៏មានវត្តមាននៅសន្និសិទសារពត៌មានខាងលើនេះដែរ ដែលកាលនោះខ្ញុំបានដើរជ្រៀតពួកអ្នកកាសែតច្រើនរូប ដើម្បីទៅសួរសុខទុក្ខលោក **Bernard Hamel** ។ គាត់ឆ្លៀតឱកាសដើម្បីនិយាយប្រាប់ខ្ញុំថា ÷ «ឧត្តមសេនិយលន់-នល់ជាមនុស្សមានប្រាជ្ញាណាស់»...។ កាលសម័យនោះ ខ្ញុំពុំមានសេចក្តីទុកចិត្តទៅលើសភាពការណ៍ប្រែប្រួលនេះទេ ។ ខ្ញុំនៅតែខំប្រឹងជឿ **Bernard Hamel** ទៅ តែខ្ញុំមានអារម្មណ៍ថា ជនជាតិខ្មែរយើងទាំងអស់គ្នា កំពុងធ្លាក់ចូលក្នុងអន្ទាក់របស់គេ...

⌘

⌘ ⌘

★★★ ដូច្នេះ នៅថ្ងៃទី៣០មិនា១៩៧០ទៅហើយ ដែលទីក្រុងភ្នំពេញកំពុងតែត្រូវឡោមព័ទ្ធជុំជិត ដោយកងទ័ពកុម្មុយនិស្តយៀកកុងនិងយួនខាងជើង, លោកឧត្តមសេនិយលន់-នល់នៅតែប្រកាសបញ្ជាក់ដល់ពិភពលោកទាំងមូលថា លោកនៅតែមានសេចក្តីស្មោះត្រង់ ចំពោះឧត្តមគតិនៃ«សង្គមរាស្ត្រនិយម»របស់សម្តេចសីហនុ ពោលរក្សាកម្ពុជាឲ្យនៅមានលក្ខណ:អព្យាក្រឹត្យមិនចូលបក្សខាងណា ។ ក៏ប៉ុន្តែគ្មាននរណាម្នាក់នៅលើលោកនេះដែលជឿថា លោកឧត្តមសេនិយលន់-នល់មិនមែនជាកូនជឹងរបស់អាមេរិកាំងនោះសោះ គឺពីព្រោះអ្នកផងគ្រប់គ្នាគេនាំគ្នាជឿពាក្យសំដីរបស់ស្តេចសីហនុ ដែលកំពុងស្រែកចំទាលពីទីក្រុងប៉េកាំងមកថា លោកឧត្តមសេនិយជាភ្នាក់ងាររបស់សេអ៊ីអា ។ តាមពិតសម្តេចសីហនុជាភ្នាក់ងារសេអ៊ីអាខ្លួនឯងទៅវិញសោះ ចំណែកលោកលន់-នល់ គឺគ្រាន់តែជាកូនត្រីប្រកៃ ឬជាកូនជឹងរបស់ស្តេច (សម្តេចសីហនុបានអះអាងនៅក្នុង **My War with C.I.A.** ថាឧត្តមសេនិយលន់-នល់ជា«ជនក្បត់ចូលអាមេរិកាំង» ជាយូរយារណាស់មកហើយ ដូច្នេះម្តេចបានជាលោកតែងតាំងឧត្តមសេនិយលន់-នល់ជានាយករដ្ឋាភិបាលនៅក្នុងឆ្នាំ១៩៦៩ ?? ។ ដូច្នេះមិនគឺសម្តេចខ្លួនឯងទេឬ ដែលជាអ្នកបង្កើតជនក្បត់ ?! មិនគឺសម្តេចខ្លួនឯងទេឬ ជាភ្នាក់ងាររបស់អាមេរិកាំង ?!)

ក្នុងប្រការចោទឧត្តមសេនិយលន់-នល់ថាជា«ជនក្បត់ធ្វើរដ្ឋប្រហារបំរើអា-

មេរិក» ប្រហែលជាពុំសូវមាននរណាជឿទ្រង់ប៉ុន្មានទេកាលពីសម័យនោះ ប្រសិនបើនៅខាងអាមេរិកាំង លោកគីស្សីងគ្ញើរ មិនបានខំប្រឹងលាបពណ៌លោកឧត្តមសេនិយលន់-នល់ ឲ្យទៅជាជនស្ដាំនិយមបែបស៊ូហារតូ... ជនសម្លាប់កុម្មុយនិស្ដដែលអាមេរិកាំងត្រូវការ ស្របដំណើរជាមួយគ្នានឹងការចោទប្រកាន់របស់សីហនុដែរ និងស្របជាមួយគ្នាដែលកំពុងតែចោទថា ឧត្តមសេនិយលន់-នល់ជា«អ្នកធ្វើរដ្ឋប្រហារទម្លាក់សម្ដេចសីហនុ និងជាអ្នកកាប់សម្លាប់យួន!!» ។

សូនអានអត្ថបទដកស្រង់មួយរបស់លោក **Jussi Hanhimäki** ៖

«វាពុំមានភស្ដុតាងអ្វីពិតប្រាកដដែលបញ្ជាក់ថា រដ្ឋការនិចសុន ឬក៏គីស្សីងគ្ញើរមានលាយឡំក្នុងគំរោងការណ៍ធ្វើរដ្ឋប្រហាររបស់លន់-នល់, ទោះជាយ៉ាងនេះក្ដី ពួកអាជ្ញាធរអាមេរិកាំងនៅវៀតណាម ព្រមទាំងពួកភ្នាក់ងារសេអ៊ីអានៅក្នុងតំបន់ (ឥណ្ឌូចិន) ច្បាស់ជាបានជ្រាបអំពីដំណើរការណ៍ទម្លាក់ស្ដេចនេះតាំងពីដំបូងដៃម្ល៉េះ ។ ទោះជាយ៉ាងណាក្ដី គីស្សីងគ្ញើរ ច្បាស់ជាបានទទួលស្វាគមន៍ចំពោះការផ្លាស់ប្ដូរនៃរដ្ឋាភិបាល យ៉ាងហោចណាស់ក៏ដោយសារតែពួកវៀតណាមខាងជើង ហាក់ដូចជាមានការ«ភ័ន្តភាំងវង្វេងវង្វាន់» ទាក់ទងទៅនឹងការរុញច្រានសីហនុឲ្យធ្លាក់ពីមុខតំណែង ។ នៅក្នុងរយៈពេលពីរសប្ដាហ៍បន្ទាប់ពីរដ្ឋប្រហារ គីស្សីងគ្ញើរ ដែលបានជួបឡេ-ឌឹកថ នៅទីក្រុងប៉ារីសបានពោលថា «ឡេ-ឌឹកថហាក់ដូចជាគ្មានលំនឹងសោះ គឺឈរជើងមិនជាប់ដី» ។ កាលនោះ គីស្សីងគ្ញើរ បានពោលប្រាប់ឡេ-ឌឹកថថា បើចង់បន្តការចរចា ពួកយៀកណាមខាងជើង«ត្រូវមានសំណើរជាវិជ្ជមាន (**positive**) ដាក់លើតុ ។ គឺជាការច្បាស់លាស់ណាស់ការទម្លាក់សីហនុ ជាការផ្លាស់ប្ដូរមួយដ៏ល្អសំរាប់ គីស្សីងគ្ញើរ » ។

«ប្រតិកម្មនៃរដ្ឋការនិចសុនភ្លាមបន្ទាប់ពីរដ្ឋប្រហារ បានបញ្ជាក់ច្បាស់ណាស់ថា លន់-នល់បានត្រូវទទួលស្វាគមន៍ ដោយចាត់ទុកថាជាទ្រព្យសម្បត្តិមួយដ៏ល្អប្រសើររបស់អាមេរិកាំង ។ ជាពិសេស និចសុនមានការពេញចិត្តនឹងគំរោងការពង្រីកកងទ័ពរបស់មេដឹកនាំថ្មីរបស់ខ្មែរ ហើយនៅថ្ងៃទី១៩មិនា បានសរសេរប្រាប់គីស្សីងគ្ញើរថា លោកចង់បានចាងហ្វាងសេអ៊ីអា **Richard Helms** រៀបចំគំរោងការជំនួយមួយពេញទំហឹង សំរាប់ពួកប្រូអាមេរិកាំងនៅប្រទេសកម្ពុជា» ។ ពីរបីអាទិត្យក្រោយមក សហរដ្ឋអាមេរិកក្រោយមក សហរដ្ឋអាមេរិកក៏បានទទួលស្គាល់លោកលន់-នល់ ព្រមទាំងបានចាប់ផ្ដើមកម្មវិធីយោធា (អន្តរាគមន៍កងទ័ព) និងជំនួយដល់កម្ពុជា មិនត្រឹមតែប៉ុណ្ណោះថែមទាំងបានអនុញ្ញាតឲ្យកងទ័ពវៀតណាមខាងត្បូង ចូលវាយលុកជំរំវៀតណាមខាងជើង (នៅក្នុងទឹកដីខ្មែរ) ដោយមានជំនួយកងអាកាសរបស់អាមេរិកាំងនៅចុងខែមិនា១៩៧០។ ដូចលោក **Haldeman** បានពោលដូច្នោះ, រដ្ឋប្រហារនេះ «វាសមស្របជាមួយនឹងចំណង់របស់យើងពិតមែន» (**The Flawed Architect, p.72**) ។

★★★ នៅក្នុងសៀវភៅទាំងអស់នេះ លោកគីស្សីងគ្ញើរដឹងច្បាស់ណាស់ថា ឧត្តមសេនិយលន់-នល់មិនបានធ្វើរដ្ឋប្រហារចុះចូលនឹងអាមេរិកាំងនោះទេ, ពីព្រោះលោកគីស្សីងគ្ញើរ បានទទួលសេចក្ដីអនុញ្ញាតពីស្ដេចសីហនុ (មិនមែនបានពីលោកលន់-នល់នោះទេ) ក្នុងប្រការពង្រីកសង្គ្រាមយួន ចូលក្នុងទឹកដីកម្ពុជា ដោយធ្វើការទម្លាក់គ្រាប់បែកសម្ងាត់នៅក្នុងទឹកដីខ្មែរ តាំងតែពីខែមិនា១៩៦៩ម្ល៉េះ ។ «កិច្ចប្រតិបត្តិការ<តារាងម្ហូប> (កកន ៖ ម្ហូបគឺគ្រាប់បែកអាមេរិកាំង សំរាប់ជាចំណីអាហារដល់ប្រជាជនកម្ពុជា) បានចាប់ផ្ដើមឡើងនៅថ្ងៃ១៨មិនា ។ ថ្ងៃស្អែកឡើង គីស្សីងគ្ញើរមានសំណើចញញឹមពព្រាយសប្បាយចិត្តណាស់ យោងតាម **Haldeman**, ដោយពត៌មានភ្លាមៗពីយុទ្ធនាការទម្លាក់គ្រាប់បែកបានឲ្យដឹងថា អាមេរិកាំងបានទទួលជោគជ័យយ៉ាងគាប់ប្រសើរ ។ នៅក្នុងរយៈពេល១៤ខែ បន្ទាប់ពីការចាប់ផ្ដើមទម្លាក់នៅក្នុងខែមិនា១៩៦៩មក, សហរដ្ឋអាមេរិកបានបញ្ជូនយន្តហោះ **B-52** ទៅធ្វើកិច្ចប្រតិបត្តិការទម្លាក់គ្រាប់បែកនៅក្នុងទឹកដីកម្ពុជាចំនួន ៣,៦៣០ដង» (**The Flawed Architect, p.44 & 45**) ។ ពោលគឺអាមេរិកាំងបានទម្លាក់គ្រាប់បែកទៅលើក្បាលជនជាតិខ្មែរ ពីខែមិនា១៩៦៩ ទៅដល់ខែមេសា១៩៧០ (យុទ្ធនាការទម្លាក់គ្រាប់បែកនេះ បានបន្តគ្មានឈប់ឈររហូតដល់ឆ្នាំ១៩៧៣) ។ ដូច្នេះ ដើម្បីលាក់បំបាំងឧក្រិដ្ឋកម្មនៃការប្រល័យពូជសាសន៍ដ៏ធំធេងហួសនិស្ស័យនេះ... លោកគីស្សីងគ្ញើរត្រូវការលាបពណ៌សំបុរឧត្តមសេនិយលន់-នល់ ជាមេដឹកនាំរដ្ឋប្រហារប្រូ-អាមេរិកាំង ស្របជាមួយគ្នានឹងសម្ដេចសីហនុ និងស្របតាមគោលការណ៍របស់ផាំ-យ៉ាំងដុង (គឺធ្វើឲ្យស្រុកខ្មែររលត់រលាយសាបសូន្យ) ។ ដើម្បីសម្លាប់ឆ្កែ គេត្រូវចោទថាឆ្កែនោះឆ្កួត, ម្ល៉ោះហើយលោកគីស្សីងគ្ញើរ បានលាបពណ៌ឧត្តមសេនិយលន់-នល់និងជនជាតិខ្មែរឲ្យឃើញជាពួកមនុស្សឆ្កួត ឥតមានហេតុផល ប្រូអាមេរិកាំងដោយគ្មានការចំណេញ, ជាពួកជនព្រៃផ្សៃ ដែលធ្វើ«រដ្ឋប្រហារទម្លាក់ស្ដេច និងកាប់សម្លាប់យួនដោយគ្មានការពិចារណា» ! ។ ដូច្នេះកំហុសនៃសង្គ្រាមនេះ គឺបណ្ដាលមកពីជនជាតិខ្មែរខ្លួនឯង !! ។ រួមសេចក្ដីទៅ លោកគីស្សីងគ្ញើរដែលបានទៅរួមប្រជុំជាមួយឡេ-ឌឹកថ នៅទីក្រុងប៉ារីសតាំងតែពីឆ្នាំ១៩៦៩ម្ល៉េះ គឺមិនមែនដើម្បីបញ្ចប់សង្គ្រាមនៅវៀតណាមទេ តែគឺដើម្បីពង្រីកសង្គ្រាមចូលក្នុងទឹកដីប្រទេសកម្ពុជាទៅវិញ ។ ក្នុងប្រការនេះ លោកគីស្សីងគ្ញើរជាជនក្បត់នៅក្នុងរដ្ឋការនិចសុន ពីព្រោះលោកមិនបានបំរើផលប្រយោជន៍របស់សហរដ្ឋអាមេរិកនោះទេ តែបានបំរើផលប្រយោជន៍របស់វៀតណាមខាងជើង ។ គឺការទម្លាក់គ្រាប់បែកសម្ងាត់ទៅលើប្រទេសកម្ពុជាក្នុងឆ្នាំ១៩៦៩ របស់លោកគីស្សីងគ្ញើរនោះហើយ ដែលបានធ្វើឲ្យរដ្ឋការនិចសុនរលត់រលាយនៅក្នុងរឿងវិបត្តិ **Watergate** នៃឆ្នាំ១៩៧៣-៧៤ ។

នៅ«ចុងខែមិនា១៩៧០»ទៅហើយ, លោកឧត្តមសេនិយលន់-នល់បានប្រកាសជាឧឡារិកចំពោះពិភពលោកទាំងមូល អំពីគោលជំហររបស់លោកជា«ជនអព្យាក្រឹត្យ» ដែលមិនអនុញ្ញាតឲ្យ«នរណាម្នាក់មកធ្វើសង្គ្រាមនៅក្នុងទឹកដីខ្មែរជំនួសខ្មែរសោះឡើយ»... តែនៅ«ចុងខែមិនា»ដដែលនោះ រដ្ឋការនិចសុន-គីស្សីងគ្ញើរបែរជាចាត់ទុកថា «សាធារណរដ្ឋរបស់លោកលន់-នល់ ជារបបប្រូអាមេរិកាំង»ទៅវិញ ។ មិនត្រឹមតែប៉ុណ្ណោះសោត ថែមទាំងបានបញ្ជូនកងទ័ពវៀតណាមខាងត្បូង ទៅចូលលុកលុយទឹកដីខ្មែរផងទៀត !! ។ នេះមិនមែនជាការលើកស្ទួយសាធារណរដ្ឋខ្មែរនោះទេ តែជាការជាន់ពន្លិចជាតិខ្មែរឲ្យស្លាប់ពីរត្រួតតែម្ដង !!

គិតទៅ លោកគីស្សីងគ្ញើរ ហើយនិងផាំ-យ៉ាំងដុងមានការវង្វេងវង្វាន់ដូចគ្នាបន្ទាប់ពីព្រឹត្តិការណ៍ទម្លាក់សីហនុ ។ ប៉ុន្ដែពីរនាក់នេះ វង្វេង«ចូល»ដូចគ្នា ពីព្រោះជាជនល្មោភសង្គ្រាមដូចគ្នា !! ។ ផាំ-យ៉ាំងដុង វង្វេងវង្វាន់បញ្ជូនទ័ព«បូដួយ»ទៅដល់ព្រំដែនខាងលិចនៃកម្ពុជា (បាត់ដំបងនិងសៀមរាប) ដើម្បី«ជួយស្ទួយរបបរបស់ស្ដេចសីហនុ» ចំណែកគីស្សីងគ្ញើរវង្វេងច្រឡំបញ្ជូនកងទ័ពវៀតណាមខាងត្បូង (៤០,០០០នាក់) ទៅភូមិភាគខាងកើតនៃប្រទេសកម្ពុជា ដើម្បី«ជួយស្ទួយរបបសាធារណរដ្ឋរបស់ឧត្តមសេនិយលន់-នល់» ឲ្យបានឆាប់ស្លាប់ !!

⌘

⌘ ⌘

★★★ សូមអានអត្ថបទមួយទៀតរបស់លោក **Jussi Hanhimäki** ៖ «នៅចុងបំផុតទៅ ការស្វែងរុករកចូលទៅក្នុងសេនាធិការកុម្មុយនិស្ដនៅប្រទេសកម្ពុជា បានក្លាយទៅជាបេសកកម្មមួយរបូតរលូត ។ អស់រយៈពេលពីរខែ, ពួកកងទ័ពយៀកណាមកុងវ៉ានិងកងទ័ពអាមេរិកាំង (ចំនួន៤០,០០០នាក់) បានចូលលុកលុយរាតត្បាតភូមិភាគខាងកើតប្រទេសកម្ពុជា បណ្ដាលឲ្យមានសភាពចលាចលវឹកវរនៅក្នុងជនបទ នៅពេលដែលពួកគេចាប់ប្រមូលបានគ្រឿងអាវុធរបស់ខ្មាំង ប៉ុន្ដែពួកគេពុំសូវជាបានជួបប្រទះនឹងទ័ពខ្មាំងដ៏ពិតប្រាកដនោះសោះ ផ្ទុយទៅវិញពួកគេបែរទៅជាបានរុញច្រានពួកកុម្មុយនិស្ដ ពោលពួកយៀកណាមខាងជើងនិងពួកខ្មែរក្រហម ឲ្យចូលកាន់តែឆ្ងាយកាន់តែជ្រៅឆ្ពោះទៅទិសខាងលិច ។ ជាលទ្ធផលការឆ្លងកាត់ចូលក្នុងទឹកដីកម្ពុជា បានបង្កើតឲ្យមានពួកជនភៀសខ្លួន ដែលកើនឡើងដូចទឹកជំនន់, ពួកអ្នកទាំងនេះមួយភាគធំបានស្វែងទៅរកទីជំរកនៅទីក្រុងភ្នំ

ពេញ ។ ក្នុងរយៈពេលតែពីរបីឆ្នាំប៉ុណ្ណោះ ប្រជាជននៅទីក្រុងនេះ (៦០០,០០០នាក់) បានកើនចំនួនលើសពីពីរដង ។ លើសពីនេះទៅទៀត នៅចុងបញ្ចប់ទៅ សង្គ្រាមបានបណ្តាលឲ្យមានមនុស្សស្លាប់កាន់តែច្រើនឡើង ក្នុងចំណោមពួកយោធានិងពួកប្រជាជនស៊ីវិល ។ បើទោះជាគ្មានបញ្ជីជាក់លាក់ដែលបង្ហាញពីចំនួនមនុស្សស្លាប់ក្តី គេអាចប៉ាន់ស្មានបានថា ជនជាតិខ្មែរដែរស្លាប់នៅចន្លោះឆ្នាំ១៩៧០និង១៩៧៣ មានចំនួនពី១០០,០០០ទៅ៣០០,០០០នាក់ ។ ក្នុងប្រការនេះ ពួកអ្នកស្រាវជ្រាវដូចជា **William Shawcross** ជាដើម ក៏បាននិយាយមិនខុសដែរ ដោយបានអះអាងថា ការរមៀលធ្លាក់នៃប្រទេសកម្ពុជា ចូលទៅក្នុងសំណាញ់របបឃាតកររបស់ប៉ុល-ពត គឺជាលទ្ធផលដ៏ចំពោះ នៃការសំរេចពង្រីកសង្គ្រាមចូលក្នុងទឹកដីកម្ពុជាដ៏អភ័ព្វនេះឯង ដែលបណ្តាលឲ្យមានសភាពហិនហោចខ្លោចផ្សារបះក្រឡាប់ ខ្ទាត់ខ្ទាយ នូវរចនាសម្ព័ន្ធនយោបាយ សង្គម និងសេដ្ឋកិច្ច...» ។

«គិតសព្វៗទៅ វាគ្មានអ្វីគួរជឿងឆ្ងល់សោះ ដែលជនអាមេរិកាំងជាច្រើនរូបមានការខកចិត្តនឹងប្រធានាធិបតីម្នាក់ ដែលបានក្បត់សេចក្តីសន្យា ។ ពីព្រោះកាលពីពីរអាទិត្យមុននោះសោះ លោកប្រធានាធិបតីបានប្រកាសដកកងទ័ពមួយចំនួនធំពីវៀតណាម ស្រាប់តែពេលឥឡូវនេះវិញ មានមុខក្រាស់បញ្ជាក់តាមទូរទស្សន៍ថា ការឆ្លងកាត់នៃកងទ័ពអាមេរិកាំង-យួនខាងត្បូងចូលក្នុងប្រទេសកម្ពុជា ពុំមែនជាការរាតត្បាតចូលក្នុងប្រទេសនេះឡើយ» ។

★★★ បូលរួមសេចក្តីទៅ លោកនិចសុនត្រូវប្រទាញដោយសីហនុនិងគីស៊្សីងគ្ញើរ ឲ្យធ្លាក់ចូលទៅក្នុងអន្ទាក់នៃសង្គ្រាមឈ្លានពានមួយ ដែលគ្មានប្រយោជន៍អ្វីសោះចំពោះប្រជាជាតិអាមេរិកាំង (ពីព្រោះគឺជាសង្គ្រាមវាតទឹកដីរបស់ផាំ-យ៉ាំងដុង) ។ ពេលលោកនិចសុនឡើងកាន់អំណាចនៅសេតវិមាន នៅដើមឆ្នាំ១៩៦៩ លោកមានគោលបំណងទៅជួបមនុស្ស២នាក់ ដែលលោកមានសេចក្តីគោរពស្មើចសរសើរ ហើយដែលសុទ្ធសឹងតែជាឪពុកធម៌របស់សម្តេចសីហនុទាំងពីរនាក់ មួយគឺឧត្តមសេនិយ ដឺគ្លោល នៅទិសខាងលិច... ពីរគឺលោកប្រធានម៉ៅ-សេទុងនៅទិសខាងកើត ។ តើលោកប្រធានាធិបតីនិចសុនបានចំពេញអ្វីដែរក្នុងប្រការពង្រីកសង្គ្រាមចូលទឹកដីកម្ពុជា ដែលមានវរជនទាំងពីរខាងលើនេះប្រកាសចេញមុខគាំពារដោយចំហ ?? ។៚

❁